ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ:២០៥៤/៣២៣

ថ្ងៃ.............ខែ.............ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី.០៥....ខែ..............ឆ្នាំ២០២៣

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមស្នងតម្លៃ

សូមអញ្ជើញក្រុមហ៊ុន/សហគ្រាសដែលមានលក្ខណសម្បត្តិចូលរួមស្នង់តម្លៃស្តីពីការផ្តល់សេវាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រនិងទូទាត់ ការិយបរិច្ឆេទ២០២៤ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

ក្រុមហ៊ុន/សហគ្រាសទាំងអស់ដែលមានចំណាប់អារម្មណ៍ អាចទាក់ទងជាមួយអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ឯកសារស្នង់តម្លៃត្រូវបានផ្តល់ជូនក្រុមហ៊ុន/សហគ្រាសដោយមិនគិតថ្លៃក្នុងរយៈពេល ០៧ថ្ងៃ ចាប់ពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣។ ក្រុមហ៊ុន/សហគ្រាសត្រូវបំពេញឯកសារស្នង់តម្លៃ ហើយប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១០:០០នាទី (ការទទួលសំណើស្នង់តម្លៃមានរយៈពេលយ៉ាងតិច ប្រាំពីរ(០៧)ថ្ងៃ គិតចាប់ពីថ្ងៃឈប់ផ្តល់ឯកសារស្នង់តម្លៃ)។

ការបើកសំណើស្នង់តម្លៃនឹងប្រព្រឹត្តទៅ នៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១០:០០នាទី ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣។

សំណើស្នង់តម្លៃរបស់ក្រុមហ៊ុន/សហគ្រាសទាំងអស់ មិនតម្រូវឱ្យមានប្រាក់កក់ធានាការដេញថ្លៃទេ។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើស្នង់តម្លៃបានតែមួយគត់។

សម្រាប់រាល់ព័ត៌មានលំអិតសូមអញ្ជើញទាក់ទងអង្គភាពលទ្ធកម្មដូចមានអាសយដ្ឋានខាងលើ ឬ តាមទូរស័ព្ទលេខ: ០១៧ ៨១១ ៩១១។

ជ. គណៈកម្មាធិការលទ្ធកម្ម
អនុប្រធាន

ជូ ផល្លា

"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ